# សុន្ទរកថា

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុង

## វេទិកាស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និង ទេសចរណ៍ កម្ពុជា - ចិន ឆ្នាំ២០១៧

## ទីក្រុងប៉េកាំង, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០១៧

***ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក លោកស្រី, ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី !***

ខ្ញុំពិតជាមានសេចក្តីរីករាយ និងកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបានចូលរួមធ្វើជាអធិបតីក្នុងពិធីបើក **វេទិកាស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងទេសចរណ៍ កម្ពុជា - ចិន ឆ្នាំ២០១៧** នាពេលនេះ ។ ក្នុងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា, ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាល និងប្រជាជនចិន ដែលតែងតែគាំទ្រជានិច្ចដល់ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច, ពាណិជ្ជកម្ម និងទេសចរណ៍នៅកម្ពុជា ។ ជាមួយគ្នានេះ, ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅផងដែរ ជូនចំពោះឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, ជាវិនិយោគិនចិន និងកម្ពុជាទាំងអស់ ដែលបានអញ្ជើញមកចូលរួមក្នុងវេទិកានេះ ។

ខ្ញុំក៏សូមអបអរសាទរ និងថ្លែងនូវការកោតសរសើរដោយស្មោះ ចំពោះកិច្ចសហការរវាងក្រសួងពាណិជ្ជកម្ម និងក្រសួងទេសចរណ៍នៃសាធារណរដ្ឋប្រជាមានិតចិន ជាមួយក្រសួងពាណិជ្ជកម្ម និងក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឱ្យវេទិកានេះអាចប្រព្រឹត្តទៅដោយរលូនតាមការគ្រោងទុក ។ ខ្ញុំមានជំនឿមុតមាំថា វេទិកានេះ មិនត្រឹមតែផ្តល់ឱកាសសម្រាប់ធុរជន និងវិនិយោគិននៃប្រទេសទាំងពីរ បានជួបពិភាក្សា និងសិក្សាស្វែងយល់ពីកាលានុវត្តភាពនិងសក្តានុពលពាណិជ្ជកម្ម និងទេសចរណ៍ប៉ុណ្ណោះទេ, ប៉ុន្តែ ថែមទាំងរួមចំណែកផងដែរដល់ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសយើងទាំងពីរ លើវិស័យពាណិជ្ជកម្ម, ឧស្សាហកម្ម, ទេសចរណ៍, វប្បធម៌, វិនិយោគ និងវិស័យផ្សេងៗទៀត ។

***ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី !***

ខ្ញុំសូមឆ្លៀតយកក្នុងឱកាសនេះ ធ្វើការវាយតម្លៃខ្ពស់ចំពោះ គោលគំនិតរបស់ **ឯកឧត្តម ស៊ី ជីនភីង** ប្រធានាធិបតីចិន ក្នុងការកែទម្រង់ស៊ីជម្រៅលើអភិបាលកិច្ចប្រទេសចិន និងក្នុងការដាក់ចេញនូវយុទ្ធសាស្ត្រ

ខ្សែក្រវ៉ាត់ និង ផ្លូវ សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលមិនត្រឹមដើរតួនាទីគន្លឹះក្នុងការជំរុញកំណើនសេដ្ឋកិច្ច និង ពាណិជ្ជកម្មចិនប៉ុណ្ណោះទេ តែក៏ជាការគិតគូរវែងឆ្ងាយ សំដៅលើកកម្ពស់ការតភ្ជាប់ និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ទាំងហេដ្ឋារចនាសម្ព័ន្ធ, សេដ្ឋកិច្ច, វិនិយោគ និងហិរញ្ញវត្ថុ ព្រមទាំងរវាងប្រជាជន និង ប្រជាជន ក្នុងចំណោមបណ្តាប្រទេស ក្នុងតំបន់ និងលើសកលលោកផងដែរ ដែលនឹងបង្កើតបាននូវ **«ក្បាលម៉ាស៊ីនថ្មីមួយក្នុងការអូសទាញកំណើនសេដ្ឋកិច្ចពិភពលោក»** ថែមទៀត ។ នៅក្នុងបរិការណ៍នៃការជំរុញអនុវត្តគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និង ផ្លូវនេះ, ទំនាក់ទំនងនៃភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិនលើគ្រប់វិស័យ ក៏ត្រូវបានពង្រឹង និងពង្រីកឱ្យកាន់តែធំធាត់ និងរឹងមាំងថែមទៀតជាលំដាប់ ពីមួយឆ្នាំទៅមួយឆ្នាំ ។

ជាការពិត, ទំនាក់ទំនងរវាងប្រទេស និងប្រជាជនយើងទាំងពីរ បានចាប់ផ្តើម និងចាក់ឫសយ៉ាងជ្រៅនៅក្នុងប្រវត្តិសាស្ត្រដ៏យូរលង់, មិនតិចជាង ២០០០ ឆ្នាំនោះទេ, បើគិតពីដំណើរទស្សនកិច្ចរបស់លោក **ការ៉ង ថៃ** និងលោក **ជូ យីង** រាជទូតចិន ដែលបានទៅបំពេញទស្សនកិច្ចនៅកម្ពុជាក្នុងសម័យហ្វូណន ។ ក្រោយមកទៀត, ក៏មានទស្សនកិច្ចរបស់ **លោក ជីវ តាក្វាន់** ទៅកាន់រាជធានីអង្គរ ដោយលោកបាននាំត្រឡប់មកកាន់ប្រទេសចិនវិញ នូវការផ្សព្វផ្សាយពីវប្បធម៌របស់ខ្មែរ ដូចមានកត់ត្រាយ៉ាងច្បាស់នៅក្នុងឯកសាររបស់លោកដែលមានចំណងជើងថា **ប្រពៃណីរបស់អ្នកស្រុកចេនឡា** ។ នេះគឺជាទំនាក់ទំនងជាប្រវត្តិសាស្ត្រដ៏យូរលង់ និងមិនអាចកាត់ថ្លៃបានរវាងប្រទេស និងប្រជាជនទាំងពីរ ។

ដោយឡែកក្នុងសម័យទំនើបនេះ ក្រោមការដឹកនាំរបស់ **សម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** និង **លោក ប្រធាន ម៉ៅ សេទុង**, ប្រទេសយើងទាំងពីរ កម្ពុជា- ចិន បានផ្សារភ្ជាប់ទំនាក់ទំនងការទូតជាមួយគ្នា នាថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៥៨ រៀងរហូតមក ។ ក្នុងស្មារតីបន្តមរតកនៃទំនាក់ទំនងដ៏ស្អិតរមួតនេះ, រូបខ្ញុំផ្ទាល់ និងថ្នាក់ដឹកនាំចិនជំនាន់ថ្មីជាបន្តបន្ទាប់ បានរួមគ្នាប្រឹងប្រែងអស់ពីសមត្ថភាព សំដៅពង្រឹង និងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការទ្វេភាគីរបស់យើងថែមទៀត រហូតបានលើកកម្ពស់ទំនាក់ទំនងនេះទៅជា **«ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ»** ចាប់ពីឆ្នាំ ២០១០ មក ។ លើសពីនេះ, កម្ពុជាក៏បានគាំទ្រយ៉ាងពេញដោយឥតរារែក, តាំងពីដើមទីមក, នូវគំនិតផ្តួចផ្តើមស្តីពី **យុទ្ធសាស្ត្រខ្សែក្រវ៉ាត់ និង ផ្លូវ សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ** របស់រដ្ឋាភិបាលចិន ។

លើមូលដ្ឋាននេះ, ទំហំពាណិជ្ជកម្មសរុបរវាងកម្ពុជា និង ចិន បានកើនឡើងយ៉ាងឆាប់រហ័សជាមធ្យម ២៦% ក្នុងមួយឆ្នាំៗ ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ។ ក្នុងឆ្នាំ ២០១៦, ពាណិជ្ជកម្មទ្វេភាគីបានកើនដល់ ៤,៨ ប៊ីលានដុល្លារអាមេរិក ក្នុងនោះ ការនាំចេញរបស់កម្ពុជាមានទំហំ ៨៣០ លានដុល្លារអាមេរិក និងការនាំចូលមានប្រមាណ ៣,៩ ប៊ីលានដុល្លារអាមេរិក ។ ចិនក៏ជាប្រទេសវិនិយោគធំជាងគេបំផុតនៅកម្ពុជា ដែលគិតមកដល់ឆ្នាំ ២០១៦ សន្និធិវិនិយោគរបស់ចិនបានកើនឡើងដល់ ៥,១ ប៊ីលានដុល្លារអាមេរិក ដែលផ្តោតទៅលើវិស័យមួយចំនួន រួមមាន កម្មន្តសាល, សំណង់, វាយនភ័ណ្ឌ និង

អត្ថិសន្និ ។ ជាមួយគ្នានេះ, នៅឆ្នាំ ២០១៦, ភ្ញៀវទេសចរណ៍ចិនមកទស្សនាកម្ពុជាមានចំនួន ៨៣០ ពាន់នាក់ កើនឡើងប្រមាណ ២០% ប្រៀបទៅនឹងឆ្នាំ ២០១៥ ។

ដោយឡែក, នៅក្នុងផ្នែកហិរញ្ញប្បទានដើម្បីការអភិវឌ្ឍ, កម្ពុជាបានទទួលជំនួយអភិវឌ្ឍន៍ផ្លូវការ, ទាំងជំនួយឥតសំណង និង កម្ចីពីសាធារណរដ្ឋប្រជាមានិតចិនរហូតដល់ ៤,២ ប៊ីលានដុល្លារអាមេរិក, គិតត្រឹមខែ កុម្ភៈ ឆ្នាំ ២០១៧ នេះ, ដែលភាគច្រើនសម្រាប់ការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, កសិកម្ម, សុខាភិបាល និង អប់រំ ។ ចំពោះមុខ, ក្រោមគំនិតផ្តួចផ្តើមនៃយុទ្ធសាស្ត្រខ្សែក្រវ៉ាត់ និង ផ្លូវ សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ ប្រទេសទាំងពីរបានបេជ្ញាបន្តពង្រីកកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយរបស់ខ្លួនលើវិស័យសំខាន់ៗ រួមមាន ការពង្រឹងផលិតភាពសេដ្ឋកិច្ច, ការបង្កើនពាណិជ្ជកម្មទ្វេភាគី, ទេសចរណ៍, វប្បធម៌, ការវិនិយោគ និង ការអភិវឌ្ឍកសិកម្ម ។ល។

នៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការថ្មីនេះ ដើម្បីគោល ដៅនៃការលើកកម្ពស់ថែមទៀតនូវការតភ្ជាប់, ពិសេសការតភ្ជាប់រវាងប្រជាជន និង ប្រជាជន, យើងបានសម្រេចបង្កើតភូមិវប្បធម៌ កម្ពុជា- ចិន នៅទីក្រុងប៉េកាំង ដែលគ្រោងនឹងសាងសង់ក្នុងពេលដ៏ខ្លីខាងមុខ ។ មួយវិញទៀត, យើងក៏បាន និងកំពុងបើកមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជានៅតាមបណ្តាខេត្តមួយចំនួននៃប្រទេសចិន ដើម្បីលើកស្ទួយការផ្លាស់ប្តូរ និងការផ្សព្វផ្សាយព័ត៌មានទៅវិញទៅមកសម្រាប់ជាប្រយោជន៍ដល់ប្រជាជន, ពាណិជ្ជករ និងវិនិយោគិនចិន ដែលមានបំណងចង់ស្វែងយល់អំពីកម្ពុជា ។ ភូមិវប្បធម៌ និងមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជាទាំងអស់នេះ មានដាក់តាំងផលិតផលផ្សេងរបស់កម្ពុជា, សៀវភៅ, ឯកសារផ្សេងៗជាច្រើនដែលពាក់ព័ន្ធ នឹងពាណិជ្ជកម្ម, ទេសចរណ៍, វប្បធម៌ និងការវិនិយោគនៅកម្ពុជា ។ បន្ថែមលើនេះ, ក្នុងគោលបំណងទាញយកផលប្រយោជន៍ពេញលេញពីឧត្តមភាពរបស់ប្រទេសយើងនីមួយៗ និងជំរុញកិច្ចសហប្រតិបត្តិការវិនិយោគឧស្សាហកម្មរវាងប្រទេសទាំងពីរ, កម្ពុជា, តំណាងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, និងសាធារណរដ្ឋប្រជាមានិតចិន, តំណាងដោយគណៈកម្មាធិការអភិវឌ្ឍន៍ និងកំណែទម្រង់ជាតិ, ក៏បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបង្កើនកិច្ចសហប្រតិបត្តិការវិនិយោគឧស្សាហកម្ម កាលពីថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១៥ នៅទីក្រុងប៉េកាំង ។

***ឯកឧត្តម, លោកជំទាវ, ខុននីញ៉ា, លោក, លោកស្រី !***

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងទៅ, កម្ពុជាបានឆ្លង កាត់ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់, ទាំងក្នុងទិដ្ឋភាពនយោបាយ, សន្តិសុខ និងសង្គម- សេដ្ឋកិច្ច ។ កម្ពុជាបានក្លាយទៅជាកោះសន្តិភាព និងជាទិសដៅដ៏ល្បីល្បាញមួយនៅតំបន់អាស៊ីអាគ្នេយ៍ សម្រាប់ភ្ញៀវទេសចរណ៍តំបន់ និងអន្តរជាតិ ។ ក្នុងទិដ្ឋភាពសេដ្ឋកិច្ចវិញ, កម្ពុជាបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងត្រូវបានគេចាត់ទុកជាកូនខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ីដែលមានកំណើនដ៏រឹងមាំ ពោលគឺ ក្នុងអត្រាជាមធ្យម ៧,៧% ក្នុងមួយឆ្នាំ ក្នុង

រយៈពេលជាង ២ ទសវត្សកន្លងមក ។ កម្ពុជារំពឹងថា នឹងបន្តរក្សាបាននូវអត្រាកំណើនមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៧% ក្នុងរយៈពេលមធ្យមខាងមុខ ដែលប្រការនេះ បង្ហាញពីវឌ្ឍនភាពក្នុងការធ្វើពិពិធកម្មវិស័យកម្មន្តសាលធុនស្រាល និងការបន្តធ្វើសមាហរណកម្មចូលទៅក្នុងខ្សែចង្វាក់ផលិតកម្មតំបន់ និងសកល ។

ទន្ទឹមនេះ, ជាមួយនឹងការបង្កើតឡើងនូវសហគមន៍សេដ្ឋកិច្ចអាស៊ាន ក៏ដូចជាការរំពឹងទុកអំពីភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយនៃតំបន់ក្នុងពេលឆាប់ៗខាងមុខ, កម្ពុជាកំពុងខិតខំជំរុញការតភ្ជាប់ខ្លួនជាមួយទីផ្សារតំបន់ ឬ **«រោងចក្រអាស៊ី»** ដែលប្រកបដោយសក្តានុពល និងថាមវន្តភាព តាមរយៈការវិនិយោគពង្រីកមូលដ្ឋានផលិតកម្ម, ការកសាង និងកែលម្អបណ្តាញដឹកជញ្ជូន និង ប្រព័ន្ធឡូជីស្ទិក, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍, ការលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម, ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ និងការកែទម្រង់ប្រព័ន្ធតតិយុត្តិ និងស្ថាប័ន ។ ជាវិធានការគោលនយោបាយជាក់ស្តែងសម្រាប់គាំទ្រចក្ខុវិស័យនេះ, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ និងកំពុងជំរុញអនុវត្តយ៉ាងសកម្មនូវ **«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ២០១៥-២០២៥»** ដែលជា **«យុទ្ធសាស្ត្រកំណើនថ្មី»** ឬ ជាផែនទីបង្ហាញផ្លូវសម្រាប់កសាងមូលដ្ឋានផលិតកម្មដែលមានតម្លៃបន្ថែមខ្ពស់ជាងមុន ហើយមានលក្ខណៈសមាហរណកម្មជាមួយនឹងខ្សែចង្វាក់តម្លៃក្នុងតំបន់ និង លើសកលលោក ។ ច្បាស់ណាស់ថា ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស គឺជាចំណុចគន្លឹះនៃគោលនយោបាយនេះ ដោយក្នុងនេះយើងបានផ្តោតអាទិភាពទៅលើវិស័យសំខាន់ៗមួយចំនួន មានៈ ទី១- ឧស្សាហកម្មកម្មន្តសាលថ្មីៗសម្រាប់បើកច្រកចូលទីផ្សារដែលផ្តល់តម្លៃបន្ថែមខ្ពស់ ព្រមទាំងមានភាពច្នៃប្រឌិត និងការប្រកួតប្រជែងខ្ពស់; ទី២- សហគ្រាសធុនតូច និងមធ្យម ពិសេស ក្នុងវិស័យនៃការផលិតឱសថ និងបរិក្ខាពេទ្យ, សម្ភារៈសំណង់, សម្ភារៈបម្រើការវេចខ្ចប់នាំចេញ, គ្រឿងសង្ហារឹម និងឧបករណ៍សម្ភារៈបម្រើឱ្យឧស្សាហកម្ម និងកសិ-ឧស្សាហកម្មដែលបម្រើឱ្យការនាំចេញ និងទីផ្សារក្នុងស្រុក; ទី៣- ប្រភេទឧស្សាហកម្មគាំទ្រដល់កសិកម្ម, ទេសចរណ៍ និងវាយនភ័ណ្ឌ ក៏ដូចជាបម្រើឱ្យខ្សែចង្វាក់ផលិតកម្មតំបន់ និងខ្សែចង្វាក់តម្លៃពិភពលោក ទាំងក្នុងទម្រង់ជាឧស្សាហកម្មអនុគមន៍ និងឧស្សាហកម្មប្រតិគមន៍; ទី៤- ប្រភេទឧស្សាហកម្មបម្រើឱ្យខ្សែចង្វាក់ផលិតកម្មតំបន់ដែលមានចរិតជាយុទ្ធសាស្ត្រ ដូចជា បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍, ថាមពល, ឧស្សាហកម្មធុនធ្ងន់, សិប្បកម្មវប្បធម៌, ប្រវត្តិសាស្ត្រប្រពៃណី និង បច្ចេកវិទ្យាបៃតង ។

***ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី !***

លើមូលដ្ឋាននេះ, ខ្ញុំសូមអញ្ជើញអស់លោកអ្នកទាំងអស់គ្នា ចូលរួមជាដៃគូជាមួយយើងខ្ញុំ តាមរយៈវិភាគទានជាក់ស្តែងនានា នៅក្នុងកិច្ចការរៀបចំអនាគតកាន់តែល្អប្រសើរឡើងសម្រាប់កម្ពុជា ។ ក្នុងនាមរាជរដ្ឋាភិបាល, ខ្ញុំសូមធានាជូនវិនិយោគិនគ្រប់រូបនូវបរិស្ថានគ្រប់បែបយ៉ាងដែលអនុគ្រោះ និងជួយជំរុញដល់ការវិនិយោគ ពិសេស គឺសន្តិភាព, សន្តិសុខ, និងស្ថិរភាពនយោបាយ ក៏ដូចជាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច

ព្រមទាំងក្របខ័ណ្ឌច្បាប់ និងស្ថាប័ន ដែលប្រកបដោយប្រសិទ្ធភាព, តម្លាភាព, គណនេយ្យភាព និងភាពអាចប៉ាន់ប្រមាណបាន ។

នៅចុងបញ្ចប់, ខ្ញុំសូមប្រកាសបើកវេទិកាស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និង ទេសចរណ៍ កម្ពុជា- ចិន ឆ្នាំ ២០១៧ ចាប់ពីពេលនេះតទៅ និងសូមជូនពរឱ្យវេទិកានេះ ប្រព្រឹត្តទៅដោយជោគជ័យ តាមការរំពឹងទុក ។

***សូមអរគុណ!***